ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៦៥៦

ចុះថ្ងៃទី ០៥-០៧-២០១២

សាលដីកា

លេខ ៖ ០៤ ក្រ.III.ស -

ចុះថ្ងៃទី ២៤-០១-២០១៣

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៣ ដោយមានសមាសភាព ដូចខាងក្រោម:

## ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted]

## ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៦៥៦ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១២ ដែលមាន:

១- ជនជាប់ចោទឈ្មោះ [redacted] ដារ៉ារិទ្ធ ហៅ ម៉ាប់ ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរជាងឈើ កើតនៅក្រុងភ្នំពេញ ទីលំនៅសព្វ[redacted] ១៣៨ សង្កាត់ផ្សារដេប៉ូ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលើវ ទោសគ្មានពីមុន។

២- ជនជាប់ចោទឈ្មោះ [redacted] មករា ហៅ មាក ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិក ភោជនីយដ្ឋាន និងផ្ទះសំណាក់សារី កើតនៅក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃ[redacted] ផ្លូវលេខ [redacted] សង្កាត់ផ្សារដេប៉ូ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលើវ ទោសគ្មានពីមុន។

ជាប់ចោទពីបទ: ចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចមុខមន្ទីរពេទ្យព្រះកុសុមៈ ផ្លូវ ២៧១ ក្រុម ១១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៦ ថ្មី នៃច្បាប់ស្ដីពី វិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

## ឯដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ២៣ នៅចំណុចមុខមន្ទីរពេទ្យព្រះកុសុមៈ

ផ្លូវលេខ ២៧១ ក្រុម ១១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ជនសង្ស័យមានឈ្មោះ នង ដារ៉ារិទ្ធ ឈ្មោះ [redacted] មករា និងឈ្មោះ ពៀច បានជិះម៉ូតូមួយគ្រឿង ហើយសមត្ថកិច្ចល្បាតមានការសង្ស័យក៏ហៅឲ្យឈប់ធ្វើការត្រួតពិនិត្យ ឃើញមានថ្នាំញៀនមួយកញ្ចប់តូចនៅក្នុងកាបូបដៃរបស់ជនសង្ស័យឈ្មោះ ពៀច ភ្លាមនោះជនសង្ស័យឈ្មោះ ពៀច ក៏រត់គេចខ្លួនបាត់ ចំណែកឯជនសង្ស័យឈ្មោះ [redacted] ដារ៉ារិទ្ធ និងឈ្មោះ [redacted] មករា ត្រួតពិនិត្យពុំឃើញមានថ្នាំញៀនឡើយ ប៉ុន្តែដោយស្ថិតក្នុងតម្រុយសង្ស័យ សមត្ថកិច្ចក៏នាំជនសង្ស័យទាំងពីរនាក់តែម្តង ហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតបានពីឈ្មោះ ពៀច ការិយាល័យជំនាញបានធ្វើតេស្តជំហានដំបូងលើក្រាមពណ៌សថ្លាជាមួយតេស្ត (Simon test) ជាលទ្ធផលមានសារជាតិញៀនប្រភេទមេតំហ្វេតាមីន។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៣ ឌ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសឈ្មោះ [redacted] ដារ៉ារិទ្ធ ហៅ ម៉ាប់ ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] មករា ហៅ មាក ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារម្នាក់ៗកំណត់ ១៨ (ដប់ប្រាំបី) ខែ។

ពីបទ ចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចមុខមន្ទីរពេទ្យព្រះកុសុមៈ ផ្លូវ ២៧១ ក្រុម ១១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០១១ តាមមាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២- វត្ថុតាងដែលចាប់យកមាន ក្រាមពណ៌សថ្លាចំនួន ០១ថង់តូច ទម្ងន់ 0,06g ត្រូវរឹបអូស។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ២៩០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ដារ៉ារិទ្ធ និងឈ្មោះ [redacted] មករា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៣ ឌ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ១ នៃសេចក្តីសម្រេច។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ជនជាប់ចោទឈ្មោះ [redacted] ដារ៉ារិទ្ធ ឆ្លើយថា ខ្លួនសុំដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនចេញ ដោយសុខចិត្តទទួលយកសេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted] មករា ឆ្លើយថា ខ្លួនសុំដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនចេញ ដោយសុខចិត្តទទួលយកសេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ដោយជនជាប់ចោទទាំងពីរនាក់សុំដកបណ្តឹងឧទ្ធរណ៍ ដូច្នេះ សុំឲ្យក្រុមប្រឹក្សាសម្រេចតាមច្បាប់។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

ជនជាប់ចោទទាំងពីរនាក់ គឺ [redacted] ដារ៉ាវិទ្ធ និង [redacted] មករា បានសុំដកបណ្តឹងឧទ្ធរណ៍ តាមលិខិតសុំដកបណ្តឹងឧទ្ធរណ៍លេខ ២៦៧ និង ២៦៨ ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០១២ វិញ។

ដូច្នេះ គួរចំណាយរឿងក្តីព្រហ្មទណ្ឌលេខ ៦៥៦ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ចេញពីបញ្ជីជំនុំជម្រះសាលាឧទ្ធរណ៍។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

ចំណាយសំណុំរឿងព្រហ្មទណ្ឌលេខ ៦៥៦ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ចេញពីបញ្ជីជំនុំជម្រះសាលាឧទ្ធរណ៍ ចាប់ពីពេលនេះតទៅ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ដារ៉ាវិទ្ធ និងឈ្មោះ [redacted] មករា។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

---

បានឃើញ
**ប្រធានសាលាឧទ្ធរណ៍**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ០៤ ខែ ០៦ ឆ្នាំ ២០១៤
**ក្រឡាបញ្ជី**